ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៦៤៨/០៥-០៧-២០១២
សាលដីកា
លេខ:១៦ក្រ.ក.១៤-០៣-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ: ៦៤៨ ចុះថ្ងៃទី០៥-០៧-២០១២ រវាង៖

-ជនជាប់ចោទឈ្មោះ [redacted] ផល្លា ហៅ អាន ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់កាហ្វេ កើតនៅភូមិអូ១ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ទីលំនៅសព្វថ្ងៃនៅ [redacted] ឪពុកឈ្មោះ [redacted] ផល ម្តាយឈ្មោះ [redacted] យាត ប្រពន្ធឈ្មោះ [redacted] គឹមណារី។ ឃុំខ្លួននៅថ្ងៃទី ០៣.០៧.២០០៧ (ដើមបណ្តឹងឧទ្ធរណ៍)

មេធាវីលោក [redacted] អូន

ត្រូវចោទពីបទ: ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅមុខសណ្ឋាគាររ៉ូយ៉ាល់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦។

- ជនរងគ្រោះឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ២១ឆ្នាំ ទីលំនៅសព្វថ្ងៃ [redacted] /





Scanned with CamScanner

## ៦រឿងហេតុមានដូចតទៅៈ

នៅថ្ងៃទី ២៨-១០-២០០៦ ម៉ោងប្រហែល១ រំលងអាធ្រាត ជនរងគ្រោះបានជិះម៉ូតូម៉ាក់ស្មាក់ពណ៌ខ្មៅ ជាមួយមិត្តភ័ក្តម្នាក់ទៀត ចេញពីភោជនីយដ្ឋានមកដល់មុខសណ្ឋាគាររ៉ូយ៉ាល់ភ្នំពេញ ក្នុងសង្កាត់ទន្លេបាសាក់មានជនល្មើសចំនួន៦នាក់ ជិះម៉ូតូ៣គ្រឿង បានជិះម៉ូតូកៀរម៉ូតូជនរងគ្រោះ ហើយជនល្មើសម្នាក់ទៀត បានលើកយកម៉ូតូជនរងគ្រោះជិះចេញទៅ។ នៅពេលសមត្ថកិច្ចខណ្ឌទួលគោកចាប់បានជនល្មើស៤នាក់ ដើមបណ្តឹងឈ្មោះ [redacted] ចំរើន បានទៅមើលមុខជនល្មើសទាំង៤ នាក់នោះ មានម្នាក់ឈ្មោះ [redacted] ផល្លា ដែលបានវាយខ្លួននៅថ្ងៃកើតហេតុ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១១១ ក្រ.២ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញដែលមានខ្លឹមសារសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ផល្លា ហៅ អាន ភេទប្រុស អាយុ២៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ(ប្រាំពីរឆ្នាំ)ពីបទប្លន់ និង ០១ឆ្នាំ(មួយឆ្នាំ) ពីបទប្រើប្រាស់អាវុធខុសច្បាប់ សរុប០៨ឆ្នាំ(ប្រាំបីឆ្នាំ) និងពិន័យជាប្រាក់៥០០.០០០រៀល(ប្រាំរយពាន់រៀល) ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅមុខសណ្ឋាគាររ៉ូយ៉ាល់ភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ កាលពីថ្ងៃទី ២៨-១០-២០០៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថាន់ទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និង គ្រាប់រំសេវ ។

២-បង្គាប់ឲ្យឈ្មោះ [redacted] ផល្លាហៅ អាន សងប្រាក់សំណងថ្លៃម៉ូតូទៅឈ្មោះ គង់ ចំរើន ១០៥០$US( មួយពាន់ហាសិបដុល្លាអាមេរិក ) ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផល្លា និង ជនរងគ្រោះឈ្មោះ [redacted] ចំរើន ជាដើមបណ្តឹងរដ្ឋប្បវេណី ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-១១-២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] ផល្លា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១១១ ក្រ២ ចុះថ្ងៃទី០៤-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញរបាយការណ៍ចុះថ្ងៃទី១៩-០៩-២០១២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

## ឆាពេលសវនាការ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំរើន (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ផល្លាហៅ អានបានឆ្លើយបញ្ជាក់ថា គេចាប់ខ្លួននៅសណ្ឋាគារខ្លួនមិនបានប្រព្រឹត្តទេ។ ពេលគេចាប់ខ្លួនភ្លាមៗប្រពន្ធខ្លួនមិនដឹងទេ បានដកហូតពីខ្លួនមានខ្សែក ចិញ្ចៀន ហើយពេលនោះខ្លួនគ្មានអាវុធទេ គេចាប់ខ្លួនឃុំថ្ងៃទី២៥-១១-២០០៦។ នៅថ្ងៃកើតហេតុ ពេលតទល់គេមិនបានសួរខ្លួនទេ ហើយខ្លួនមានសំណុំរឿងផ្សេងតែមិនដឹងដល់ត្រឹមណាទេ ។ សំណូមពរសុំស្រាលទោស និងសុំដូចមេធាវីខ្លួនសុំ

-តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋានៈ សុំតុលាការពិចារណាចម្លើយជនជាប់ចោទផ្ទុយអង្គហេតុ សុំសំរេច។

១៧៥

Scanned with CamScanner

មេធាវីការពារជនជាប់ចោទផ្តល់សេចក្តីសន្និដ្ឋាន៖ ក្នុងរឿងនេះ មានលក្ខណៈស្មុគ្រស្មាញដូចតំណាងអយ្យការសន្និដ្ឋាន ហើយចម្លើយជនជាប់ចោទថា ថ្ងៃកើតហេតុខ្លួននៅសណ្ឋាគារជាមួយប្រពន្ធ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន ។ សុំក្រុមប្រឹក្សាពិចារណា ប្លន់ត្រូវប្រើអាវុធ តែគ្មានអាវុធទេ ពេលចាប់ខ្លួនពេលថ្ងៃ ឯ កើតហេតុម៉ោង១,១៤នាទីយប់ ។ សុំឲ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ។

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-១១-២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] ផល្លា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១១១ក្រ២ប- ចុះថ្ងៃទី០៤-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទបានឆ្លើយបដិសេធការចោទប្រកាន់ ប៉ុន្តែជនរងគ្រោះបានស្គាល់ និងចំណាំមុខជនជាប់ចោទបានច្បាស់ អាចឲ្យតុលាការជឿបានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់។

៣-សាលក្រមព្រហ្មទណ្ឌលេខ១១១ ក្រ២ប- ចុះថ្ងៃទី០៤-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមខាងលើទុកជាបានការ។

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-១១-២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] ផល្លា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១១១ ក្រ២ប- ចុះថ្ងៃទី០៤-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ ។

៣- បន្តឃុំខ្លួនជនជាប់ចោទខាងលើ តាមនីតិវិធី ។

សាលដីកានេះជំនុំជំរះ ចំពោះមុខមេធាវីការពារជនជាប់ចោទ ជនជាប់ចោទឈ្មោះ ភោគ ផល្លា ប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានិងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍

ជាតិ សាសនា ព្រះមហាក្សត្រ

##### ដីកាសម្រេច

### ក្រុមប្រឹក្សាជំនុំជំរះទី ៤ នៃសាលាឧទ្ធរណ៍

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៦៤៨ចុះថ្ងៃទី ០៥-០៧-២០១២ របស់សាលាឧទ្ធរណ៍

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៦ក្រ IV ត ចុះថ្ងៃទី ១៤-០៣-២០១៣ របស់សាលាឧទ្ធរណ៍ ។

ក្រោយពីបានពិនិត្យឡើងវិញឃើញថា ក្នុងសាលដីកាព្រហ្មទណ្ឌលេខ១៦ក្រIVត ចុះថ្ងៃទី ១៤-០៣-២០១៣ របស់សាលាឧទ្ធរណ៍មានចំណុចភាន់ច្រឡំដោយអចេតនានៅទំព័រទី៣ ក្នុងចំណុចសំអាងហេតុ និង សេចក្តីសម្រេច ត្រង់សាលក្រមព្រហ្មទណ្ឌលេខ១១ក្រ២ ប ចុះថ្ងៃទី ០៤-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ បានដាក់សាលក្រមខុសពីសំណុំរឿង ។

### យល់ឃើញថា

គប្បីកែតម្រូវ សាលដីកាព្រហ្មទណ្ឌលេខ១៦ក្រIV ត ចុះថ្ងៃទី ១៤-០៣-២០១៣ របស់សាលាឧទ្ធរណ៍ នៅទំព័រទី៣ ក្នុងចំណុចសំអាងហេតុនិងសេចក្តីសម្រេច ត្រង់សាលក្រមព្រហ្មទណ្ឌលេខ១១ក្រ២ ប ចុះថ្ងៃទី ០៤-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ឱ្យបានត្រឹមត្រូវឡើងវិញ ។

### ហេតុដូច្នេះសម្រេច

**កែតម្រូវ** សាលដីកាព្រហ្មទណ្ឌលេខ១៦ក្រIV ត ចុះថ្ងៃទី ១៤-០៣-២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលក្រមព្រហ្មទណ្ឌលេខ១១ក្រ២ ប ចុះថ្ងៃទី ០៤-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ មកជា សាលក្រមព្រហ្មទណ្ឌលេខ១១ក្រ ២ ចុះថ្ងៃទី ០៤-១១-២០០៨វិញ។

**ចៅក្រមប្រឹក្សា** — ហត្ថលេខា : [redacted]

**ប្រធានក្រុមប្រឹក្សា** — ហត្ថលេខា : [redacted]

---

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១៤

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ... ខែ ឧសភា ឆ្នាំ 2014.

[redacted]

១៧៧

Scanned with CamScanner